# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី១ លេខ៤ ត្រីមាសទី៤ ឆ្នាំ២០២៤



រៀបរៀងដោយៈ
អគ្គលេខាធិការដ្ឋាន នៃសមាគមឧកញ៉ាកម្ពុជា

# មាតិកា


- ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាចូលរួមព្រឹត្តិការណ៍អបអរសាទរខួប២០ឆ្នាំនៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO)......................................................................................................១
- អ្នកឧកញ៉ា លាង ម៉េង ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបរមរតនកោដ្ឋក្នុងទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ..........................................................................................៤
- លោកអ្នកឧកញ៉ា លាង យុន ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ទទួលជួបសំណេះសំណាលសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូ នៃសមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចចិន-អាស៊ី......................................................................៧
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងដំណើរបំពេញទស្សនកិច្ចនៅទ្វីបអឺរ៉ុបពីថ្ងៃទី៣ ដល់ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤...............១១
- លោកជំទាវឧកញ៉ា កង លាប ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងបានបន្តថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៧១ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា.............................................................................................................២០
- លោកអ្នកឧកញ៉ា លី ហួរ ចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និង មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ........................................................................................................២២
- ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមជាអធិបតី និងជាភ្ញៀវកិត្តិយសក្នុង ពិធីជប់លៀងអបអរគម្រប់ខួប ១០ឆ្នាំ របស់មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ ..............................................................................................២៥
- សមាគមឧកញ៉ាកម្ពុជា សហការជាមួយ សមាគមជប៉ុន-កម្ពុជា បានរៀបចំពិធីបើក «ជំនួបផ្គូផ្គងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងសមាគមជប៉ុន-កម្ពុជា ២០២៤» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា.....................................................................................២៧
- អ្នកឧកញ៉ា សៀ ឫទ្ធី តំណាងសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមជាកិត្តិយស និងថ្លែងសុន្ទរកថាចំណាប់អារម្មណ៍ចូលរួមក្នុង «ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (CDC Investment Project Management System ហៅកាត់ថា ប្រព័ន្ធ cdcIPM) ដំណាក់កាលទី១» ...........................................................៣១
- លោកអ្នកឧកញ៉ា លី ហួរ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ជួបសំណេះសំណាលជាមួយប្រតិភូនៃសភាពាណិជ្ជកម្មកម្ពុជារដ្ឋកាលីហ្វ័រញ៉ា ដឹកនាំដោយលោក គីមឆា ហួត អគ្គកុងស៊ុលកិត្តិយស និងជាប្រធានការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាប្រចាំរដ្ឋកាលីហ្វ័រញ៉ា..................................................................................................៣៣
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូនៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសិកា លី យីម ដែលត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា ហ៊ុន ឡាក់...........................................................................៣៦
- ថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ទីក្រុងមេគង្គឃី (Mekong Quay City) ស្ថិតនៅក្រុងអរិយក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ...............................................................................................................៣៨

- សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារនៅវិមានសន្តិភាព........................................................................៤០
- អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំ និងជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ ឡាយ ង៉ោ ដែលត្រូវជាម្ដាយបង្កើតរបស់ អ្នកឧកញ៉ា ហេង សៀ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ..................................................................................................៤៣

## ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាចូលរួមព្រឹត្តិការណ៍អបអរសាទរខួប ២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO)

នាព្រឹកថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហាន់ ឃាង អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ៨រូបចូលរួមក្នុង «ព្រឹត្តិការណ៍អបអរសាទរខួប ២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO)» ដែលបានប្រារព្ធធ្វើឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**សម្តេចធិបតី** បានមានប្រសាសន៍ថា៖ « នៅក្នុងរយៈពេល ២០ឆ្នាំកន្លងទៅនេះ លទ្ធផលដែលយើងទាញបានតាមរយៈការកែប្រែពីភាពឯកោរបស់យើងទាំងការទូតនិងទាំងសេដ្ឋកិច្ចគឺយើងចូលទៅក្នុងសមាហរណកម្មជាមួយនឹងយន្តការពហុភាគី និងយន្តការតំបន់ដែលធ្វើឲ្យកម្ពុជារីកចម្រើនជាបន្តបន្ទាប់។ »








សូមបញ្ជាក់ថា ព្រឹត្តិការណ៍នេះ ធ្វើឡើងក្នុងគោលបំណងរំលឹកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ បន្ទាប់ពីការចរចាដ៏សកម្មរបស់ឥស្សរជនជាន់ខ្ពស់កម្ពុជា និងមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ព្រមទាំងបើកបង្ហាញនូវការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោករួមទាំងសមិទ្ធផលសេដ្ឋកិច្ចសង្គមនិងពាណិជ្ជកម្មសំខាន់ៗដែលកម្ពុជាសម្រេចបានក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ។សមាជិកភាពរបស់កម្ពុជានៅក្នុងអង្គការ WTO ជាង២ទសវត្សរ៍មកនេះ បានរួមចំណែកដល់កំណើនសេដ្ឋកិច្ចដោយធ្វើឱ្យប្រសើរឡើងនូវឱកាសពាណិជ្ជកម្ម, ជំរុញការវិនិយោគ និងគាំទ្រការអភិវឌ្ឍតាមរយៈសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្មសកល ដូចខាងក្រោម៖

១. ច្រកចូលទីផ្សាសកល៖ កម្ពុជាទទួលបានច្រកចូលទីផ្សារអន្តរជាតិល្អប្រសើរ តាមរយៈគោលការណ៍ប្រជាជាតិអនុគ្រោះបំផុត (Most Favored Nation (MFN) Principle) ដែលមានន័យថា សមាជិកអង្គការ WTO ដទៃទៀតត្រូវតែផ្តល់ឱ្យកម្ពុជានូវផលប្រយោជន៍ពាណិជ្ជកម្មដូចគ្នា ដូចជាការកាត់បន្ថយពន្ធគយ ដែលពួកគេបានផ្តល់ទៅឱ្យប្រទេសសមាជិកផ្សេងទៀតជាដើម។ ក្នុងនោះផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០០៤ មានប្រមាណ ៥,៣ ពាន់លានដុល្លារអាម៉េរិក ខណៈពេលក្នុងឆ្នាំ២០២២ បានកើនរហូតដល់ ២៩,៦១ ពាន់លានដុល្លារអាម៉េរិក។ ចំណែកការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងពី ១១០លានដុល្លារអាម៉េរិក នៅឆ្នាំ២០០០ រហូតដល់ ៤,៩ ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០២៣។ចំពោះទំហំពាណិជ្ជកម្មរបស់កម្ពុជាមានប្រមាណ ៤,៥ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០០៤ និងបានកើនឡើងជាបន្តបន្ទាប់រហូតដល់ ៤៦,៨២ ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០២៣ ក្នុងនោះការនាំចេញសរុបរបស់កម្ពុជាមានប្រមាណ២២,៦៤ពាន់លានដុល្លារអាម៉េរិក។ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជារួមមាន៖ ប្រទេសចិន, សហរដ្ឋអាម៉េរិក, សហភាពអឺរ៉ុប, ជប៉ុន, ថៃឡង់ដ៏, វៀតណាម និងកូរ៉េខាងត្បូង។ ទំនាក់ទំនងពាណិជ្ជកម្មទាំងនេះគឺស្ថិតនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគីនិងទ្វេភាគីព្រមទាំងតាមរយៈអាស៊ានដែលជំរុញសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងសមាហរណកម្មតំបន់នៅក្នុងអាស៊ីអាគ្នេយ៍។

២. ការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយពាណិជ្ជកម្ម និងកំណែទម្រង់៖ កម្ពុជាបានធ្វើកំណែទម្រង់គោលនយោបាយពាណិជ្ជកម្ម ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដោយស្របទៅតាមការប្តេជ្ញាចិត្តនៅក្រោមអង្គការ WTO។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ និងវិសោធនកម្មច្បាប់ពាក់ព័ន្ធពាណិជ្ជកម្មជាច្រើន រួមមាន៖ ច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងចុះបញ្ជីពាណិជ្ជកម្ម និងច្បាប់វិនិយោគថ្មី ជាដើម។

៣. ការធ្វើពិពិធកម្មការនាំចេញ៖ កម្ពុជាបានទាញយកឱកាសពីសមាជិកភាពអង្គការ WTO ដើម្បីធ្វើពិពិធកម្មទីផ្សារនាំចេញដែលពីមុនកម្ពុជាបានពឹងផ្អែកលើវិស័យមួយចំនួនដូចជា សម្លៀកបំពាក់ និងវាយនភ័ណ្ឌ ប៉ុន្តែបច្ចុប្បន្ន កម្ពុជាបានពង្រីកទៅក្នុងវិស័យដទៃទៀតដូចជា គ្រឿងអេឡិចត្រូនិក, ស្រូវនិងអង្ករ, កៅស៊ូ, គ្រាប់ស្វាយចន្ទី, ចេក, បន្ទះសូឡា និងកង់ព្រមទាំងផលិតផលជាច្រើនទៀត។

៤. ជំនួយបច្ចេកទេសនិងការកសាងសមត្ថភាព៖ កម្ពុជាទទួលបានកម្មវិធីជំនួយបច្ចេកទេសនិងការកសាងសមត្ថភាពពីអង្គការ WTO និងអង្គការអន្តរជាតិនានា ដើម្បីជួយពង្រឹងគោលនយោបាយពាណិជ្ជកម្ម និងស្ថាប័ន ដែលបានធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលរួមក្នុងការចរចាពាណិជ្ជកម្មអន្តរជាតិ និងការអនុវត្តកិច្ចព្រមព្រៀងអង្គការ WTO ឱ្យមានប្រសិទ្ធភាព។

៥. ការចូលរួមក្នុងគោលនយោបាយពាណិជ្ជកម្មសកល៖ សមាជិកភាពអង្គការ WTO បានអនុញ្ញាតឱ្យកម្ពុជាចូលរួមនៅក្នុងការពិភាក្សាគោលនយោបាយពាណិជ្ជកម្មសកលនិងការចរចានានាដែលបានផ្តល់ឱ្យកម្ពុជានូវសំឡេងមួយក្នុង

ការរៀបចំវិធានពាណិជ្ជកម្មអន្តរជាតិ ដែលធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

៦. ប្រព្រឹត្តិកម្មពិសេស និងដោយឡែក៖ ក្នុងនាមជាប្រទេសអភិឌ្ឍតិចតួច កម្ពុជាទទួលផលពីបទបញ្ញត្តិទាក់ទងនឹងប្រព្រឹត្តិកម្មពិសេស និងដោយឡែក (Special and Differential Treatment-SDT) ដែលផ្តល់ភាពបត់បែនបន្ថែមក្នុងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយចំនួន។បន្ថែមលើនេះកម្ពុជាទទួលបានច្រកចូលទីផ្សារដោយមិនជាប់ពន្ធគយនិងមិនជាប់កូតា(Duty-FreeQuota-Free),កម្មវិធីEBAរបស់សហភាពអឺរ៉ុបដែលបានអនុញ្ញាតឱ្យកម្ពុជានាំចេញផលិតផលទាំងអស់ដោយរួចពន្ធលើកលែងតែសព្វាវុធ និងគ្រឿងផ្ទុះ, ប្រព័ន្ធ GSP ពីសហរដ្ឋអាម៉េរិកជាដើម។

៧. ការកាត់បន្ថយភាពក្រីក្រ៖  អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយពី ៦០% ក្នុងឆ្នាំ២០០០ មកត្រឹម ១៦% ក្នុងឆ្នាំ២០២២។

៨. ការចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍតិចតួច៖ កម្ពុជាត្រូវបានគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិផ្តល់អនុសាសន៍ឱ្យចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩ បន្ទាប់ពីកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់នេះតាំងពីឆ្នាំ១៩៩១។
















**អ្នកឧកញ៉ា លាង ម៉េង ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបរមរតនកោដ្ឋ ក្នុងទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**

ព្រឹកថ្ងៃអង្គារ ១៣កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៤ អ្នកឧកញ៉ា លាង ម៉េង អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ដើម្បីថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** នៅមណ្ឌបតម្កល់ព្រះបរមរូបខាងកើតវិមានឯករាជ្យដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាចំនួន ១៨រូប។

សូមបញ្ជាក់ថា **ព្រះករុណាព្រះបរមរតនកោដ្ឋ** ព្រះរាជប្រសូត្រនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ និងជាព្រះរាជបុត្រានៃ **ព្រះបាទសម្តេច ព្រះនរោត្តម សុរាម្រឹត ព្រះមហាកញ្ញនកោដ្ឋ និងសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរតន៍ សិរីវឌ្ឍនា**។ ព្រះអង្គបានលះបង់អស់ព្រះកាយពល និងព្រះរាជបញ្ញាញាណដើម្បីបំពេញព្រះរាជកិច្ចសំខាន់ៗសម្រាប់ប្រជាជាតិខ្មែរដោយបានទាមទារឯករាជ្យពេញលេញជូនជាតិមាតុភូមិពីអាណានិគមបារាំង និងបានកសាងនូវហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាដឹកនាំព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនគ្រប់វិស័យ។

**ព្រះមហាវីរក្សត្រ** បានសោយទិវង្គតនាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ នារដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិនហើយត្រូវបានដង្ហែព្រះបរមសពមកកាន់ព្រះរាជាណាចក្រកម្ពុជាដើម្បីប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើងតាមព្រះរាជបវេណីប្រកបដោយក្តីទុក្ខសោកសង្រេងរបស់ប្រជាជនខ្មែរនៅទូទាំងប្រទេស។

ទូលបង្គំនិងខ្ញុំម្ចាស់ទាំងអស់គ្នាសូមក្រាបបង្គំថ្វាយព្រះរាជកុសលនិងសូមថ្វាយព្រះរាជកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត និងសូមចងចាំជានិច្ចនូវគុណូបការៈដ៏មានតម្លៃមិនអាចកាត់ថ្លៃបានដែលព្រះអង្គបានបន្សល់ទុកសម្រាប់ប្រជាជាតិខ្មែរជាទីស្រលាញ់របស់ព្រះអង្គ។


































## លោកអ្នកឧកញ៉ា លាង យុន ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ទទួលជួបសំណេះសំណាលសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូ នៃសមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចចិន-អាស៊ី



រសៀលថ្ងៃអង្គារ ៥រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លាង យុន អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បាន ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ទទួលជួបសំណេះសំណាលសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូ នៃសមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចចិន-អាស៊ី ដឹកនាំដោយលោក Chen Jun ដែលជាអនុប្រធានប្រតិបត្តិ និង ជាអគ្គលេខាធិការអមដោយធុរជនជាច្រើនរូបទៀតមកពីសាធារណរដ្ឋប្រជាមានិតចិន។

ជាកិច្ចចាប់ផ្តើម លោកអ្នកឧកញ៉ា លាង យុន បានមានមតិស្វាគមន៍និងជម្រាបជូនប្រតិភូសមាគមអភិវឌ្ឍន៍ សេដ្ឋកិច្ចចិន–អាស៊ីអំពីចក្ខុវិស័យក៏ដូចជាបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជាដែលប្រមូលផ្តុំដោយសមាជិកដែល សុទ្ធសឹងជាពាណិជ្ជករដ៏មានសក្តានុពលហើយកំពុងគ្រប់គ្រងអាជីវកម្មលើពហុវិស័យហើយបានរួមចំណែកជាច្រើន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការបង្កើតការងារនិងសកម្មភាពពាណិជ្ជកម្មក៏ដូចជាការវិនិយោគផងដែរ។ទន្ទឹម នឹងនោះ លោកអ្នកឧកញ៉ា បានបន្ថែមថា តាមរយៈជំនួបនាថ្ងៃនេះនឹងបើកនូវទំព័រថ្មីសម្រាប់សមាគមទាំងពីរក្នុងការ ពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកឈានទៅរកការផ្គូផ្គងពាណិជ្ជកម្មឬការ ចាប់ដៃគូរវាងសមាជិកនៃភាគីទាំងពីរ ខណៈដែលប្រទេសកម្ពុជា និងចិន គឺជាដៃគូដែកថែបនិងជាទីផ្សារដ៏ធំសម្រាប់ កម្ពុជា។

ជាការឆ្លើយតប លោក Chen Jun បានលើកឡើងថា តាងនាមសមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចចិន-អាស៊ី និង ក្នុងនាមលោកផ្ទាល់លោកមានក្តីរីករាយប្រកបដោយកិត្តិយសដែលសមាគមឧកញ៉ាកម្ពុជាបានអនុញ្ញាតដល់រូបលោក និងធុរជនចិនជាច្រើនរូបទៀតបានចូលជួបសំណេះសំណាលនិងពិភាក្សាការងារដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការ លើផ្នែកធុរកិច្ចរវាងស្ថាប័នទាំងពីរខណៈដែលសមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចចិន-អាស៊ីមានសមាជិកជាង២ម៉ឺននាក់និង មានសាខាជាង ៦០នៅក្នុងប្រទេសចិននិងមានការិយាល័យតំណាងចំនួន ១៥នៅក្នុងទ្វីបអឺរ៉ុប អាស៊ី និងសហរដ្ឋ អាម៉េរិក។

លោកបានបញ្ជាក់ថា សម្រាប់ដំណើរទស្សនកិច្ចលើកនេះ មានការចូលរួមពីថ្នាក់ដឹកនាំនៃក្រុមហ៊ុនធំៗដែលកំពុងវិនិយោគលើវិស័យបច្ចេកវិទ្យានិងនវានុវត្តន៍សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្មដូចជាក្រុមហ៊ុនBeijingDabeinong Technology Group, Beijing Aike Nong Technology Co., Ltd., Beijing Binzhi Technology Co., Ltd. និងក្រុមហ៊ុន Chirui Agricultural Services (Agricultural Machinery) ដោយវិនិយោគិនទាំងនេះសុទ្ធតែមានចំណាប់អារម្មណ៍លើវិស័យកសិកម្មនៅកម្ពុជាដែលមានសក្ដានុពលខ្ពស់ក្នុងវិស័យកសិ–ឧស្សាហកម្មនិងមានផលិតផលកសិកម្មដែលមានសក្ដានុពលជាច្រើនដូចជា ស្រូវ កៅស៊ូ ដំឡូងមី ស្វាយចន្ទី ចេក និងម្រេចជាដើម។

លោកអគ្គលេខាធិការ មានសុទិដ្ឋិនិយមថា សមាគមទាំងពីរនឹងអាចសម្រេចបានកិច្ចសហការនាពេលដ៏ខ្លីខាងមុខតាមរយៈការបង្កើតនូវយន្តការពិភាក្សាបន្ថែមទៀត, ការបង្កើតកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងការបង្កើតឱ្យមានវេទិកាធុរកិច្ចយ៉ាងតិច ១ឆ្នាំម្ដងដើម្បីឱ្យសមាជិកនៃសមាគមទាំងពីរបានជួបពិភាក្សា និងចាប់ដៃគូធុរកិច្ចជាមួយគ្នាទៅវិញទៅមក។

















ជាមួយគ្នានេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា ព្រមទាំងលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ដែលជាថ្នាក់ដឹកនាំសមាគម បានមានមតិស្វាគមន៍ក៏ដូចជាបានណែនាំអំពីសមាសភាពនិងអាជីវកម្មរៀងៗខ្លួនដែលសុទ្ធតែមានកាលានុវត្តភាពក្នុងការវិនិយោគជាមួយភាគីចិនដូចជា កំពង់ផែ ស្ពានឧស្សាហកម្មកសិកម្ម កសិ-ឧស្សាហកម្ម ថាមពលអគ្គិសនី សំណង់ និងរោងចក្រផលិតចំណីអាហារជាដើម។ បន្ថែមពីលើនេះ ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជា ក៏បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនក្នុងវិស័យកសិកម្មរួមមាន កត្តាបច្ចេកទេស គ្រាប់ពូជ អ្នកជំនាញ បច្ចេកវិទ្យាថ្មីៗ ការកែច្នៃ តម្រូវការរោងម៉ាស៊ីនកិនស្រូវធំៗ ឡសម្ងួត ក៏ដូចជាការដឹកជញ្ជូនផងដែរ និងបានលើកសំណើដល់ភាគីចិនព្យាយាមគៀងគរនូវវិនិយោគិនដែលមានសក្តានុពលមកកាន់កម្ពុជាបន្ថែមទៀត ខណៈដែលសមាគមឧកញ៉ាកម្ពុជា បានត្រៀមខ្លួនរួចជាស្រេចក្នុងការបំពេញកិច្ចសហប្រតិបត្តិការនានាដើម្បីជាគុណប្រយោជន៍ដល់ប្រជាកសិករនិងការអភិវឌ្ឍវិស័យកសិកម្មក្នុងប្រទេសដើម្បីប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់ និងជាពិសេសគឺការបំពេញគ្រប់លក្ខខណ្ឌតម្រូវដើម្បីនាំចេញកសិផលទៅកាន់ប្រទេសចិនតែម្តង។

ជាការកត់សម្គាល់ ភាគីប្រតិភូចិន បានគាំទ្រចំពោះសំណើទាំងនេះនឹងបានបង្ហាញនូវជំនឿចិត្តថា ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជា នឹងផ្តល់ការគាំទ្រយ៉ាងពេញទំហឹងចំពោះបេសកកម្មរបស់សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចចិន–អាស៊ីប្រចាំនៅកម្ពុជាហើយជាពិសេសនឹងមានកិច្ចសន្ទនាជាមួយគ្នាជាប្រចាំដើម្បីផ្លាស់ប្តូរព័ត៌មាននិងកាលានុវត្តភាពពាណិជ្ជកម្ម និងការវិនិយោគតាមរយៈការផ្គូផ្គងធុរកិច្ចរវាងសមាជិកនៃសមាគមទាំងពីរ។

តាមរយៈកិច្ចពិភាក្សាយ៉ាងផុសផុលភាគីទាំងពីរបានឯកភាពឱ្យមានការជួបពិភាក្សាគ្នាបន្ថែមទៀតដើម្បីឈានទៅរកកិច្ចសហប្រតិបត្តិការនានាដែលនឹងនាំមកនូវអត្ថប្រយោជន៍ដល់ភាគីទាំងពីរជាពិសេសការអភិវឌ្ឍលើវិស័យកសិកម្មព្រមទាំងវិស័យផ្សេងៗទៀតដែលជាសក្តានុពលរបស់កម្ពុជា។














Sun Wei
Fu Jian
Chen Jun




Fu Jian



## គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងដំណើរបំពេញទស្សនកិច្ចនៅទ្វីបអឺរ៉ុបពីថ្ងៃទី៣ ដល់ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិនឹងដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលមានសមាសភាពដូចជា អ្នកឧកញ៉ា ហ៊ុន ឡាក់ ជំទាវអ្នកឧកញ៉ា គួន ធីតា និង ឧកញ៉ា លាង ពៅ ដើម្បីចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅសាធារណរដ្ឋបារាំង សាធារណរដ្ឋឆែក និងចក្រភពអង់គ្លេសដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤។

បេសកកម្មនេះត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងគោលបំណងផ្សព្វផ្សាយផ្តល់និងធ្វើបច្ចុប្បន្នភាពអំពីកាលានុវត្តភាពវិនិយោគជូនដល់ធុរជនព្រមទាំងវិនិយោគិនដែលមានសក្តានុពល និងមានចំណាប់អារម្មណ៍ក្នុងការមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែច្រើនឡើងថែមទៀត។











## គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងដំណើរបំពេញទស្សនកិច្ចនៅទីស្នាក់ការកណ្តាលក្រុមហ៊ុន CMA CGM

ជាកិច្ចចាប់ផ្តើមបេសកកម្ម អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន WorldBridge Group បានចូលរួមអមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងដំណើរអញ្ជើញចុះបំពេញទស្សនកិច្ចនៅទីស្នាក់ការកណ្តាលក្រុមហ៊ុន CMA CGM ដែលជាក្រុមហ៊ុនដឹកជញ្ជូន និងភស្តុភារកម្មរបស់បារាំង ក្រោមការសម្របសម្រួលពីលោកស្រី Natalie Garro ដែលជាប្រធានអង្គភាពអាជីវកម្ម។

ក្នុងឱកាសនោះ ថ្នាក់ដឹកនាំក្រុមហ៊ុនបានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់ប្រតិភូកម្ពុជា និងបានធ្វើបទបង្ហាញជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អំពីប្រព័ន្ធបច្ចេកវិទ្យាក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនព្រមទាំងភ្ជាប់នឹងបច្ចុប្បន្នភាពនៃវិស័យដឹកជញ្ជូន និងភស្តុភារកម្មផងដែរ។ក្រុមហ៊ុនក៏បានបង្ហាញចំណាប់អារម្មណ៍លើវឌ្ឍនភាពនិងការផ្លាស់ប្តូរមុខមាត់របស់កម្ពុជាលើវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនពិសេសថ្មីៗនេះបានបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោសម្រាប់គម្រោងដឹកជញ្ជូនផ្លូវទឹក។

តបតាមបទបង្ហាញនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់ក្រុមហ៊ុនដែលបានផ្តល់ការគិតគូរលើគម្រោងព្រែកជីកហ្វូណនតេជោរបស់កម្ពុជា។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានបង្ហាញជូនអំពីវឌ្ឍនភាពនិងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនរាប់បញ្ចូលទាំងវិស័យដឹកជញ្ជូនផ្លូវទឹកនិងកំពង់ផែជាដើម។ស្របតាមឱកាសនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានជំរុញទឹកចិត្តឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាពក្នុងការចូលរួមសកម្មភាពនានាបន្ថែមទៀត ព្រមទាំងបណ្តាក់ទុនវិនិយោគលើវិស័យដឹកជញ្ជូន និងភស្តុភារកម្មនៅកម្ពុជា។













## ដំណើរបំពេញទស្សនកិច្ចផ្សារ Rungis Wholesale Market ដែលជាផ្សារបោះដុំធំមួយក្នុងប្រទេសបារាំង និង បន្តអញ្ជើញពិសាអាហារធុរកិច្ចជាមួយលោក St"phane Layaniនាយកប្រតិបត្តិក្រុមហ៊ុន SEMMARIS

បន្ទាប់មកទៀតនាថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអញ្ជើញបំពេញទស្សនកិច្ចផ្សារ Rungis Wholesale Market ដែលជាផ្សារបោះដុំធំមួយក្នុងប្រទេសបារាំង និងបន្តអញ្ជើញពិសាអាហារធុរកិច្ចជាមួយលោក Stéphane Layani នាយកប្រតិបត្តិក្រុមហ៊ុន SEMMARIS ផងដែរកាលពីថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ កន្លងទៅថ្មីៗនេះ។

ក្នុងដំណើរទស្សនកិច្ចនាឱកាសនេះថ្នាក់ដឹកនាំក្រុមហ៊ុនបានផ្តល់ការស្វាគមន៍យ៉ាងកក់ក្តៅចំពោះប្រតិភូកម្ពុជា និងបានធ្វើបទបង្ហាញជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អំពីបច្ចុប្បន្នភាពនៃផ្សារ Rungis Wholesale Market ដែលធ្វើការបោះដុំ និងផ្គត់ផ្គង់អាហារដ៏ធំមួយក្នុងប្រទេសបារាំង។
















## ប្រតិភូកម្ពុជាបំពេញទស្សនកិច្ចនៅទីស្នាក់ការកណ្តាលអគ្គិសនីបារាំង (Electricit" de France_EDF) និង ក្រុមប្រឹក្សាប្រតិបត្តិមួយចំនួនទៀតរបស់ EDF នាក្រុងប៉ារីស ព្រមទាំងថ្នាក់ដឹកនាំក្រុមហ៊ុនមួយចំនួនទៀត

គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានបន្តអមដំណើរឯកឧត្តមស៊ុនចាន់ថុលឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឱកាសជួបពិភាក្សាការងារជាមួយលោក Erkki Maillard ទីប្រឹក្សាការទូតរបស់អគ្គិសនីបារាំង (Electricité de France_EDF) និងក្រុមប្រឹក្សាប្រតិបត្តិមួយចំនួនទៀតរបស់ EDF នៅទីស្នាក់ការកណ្តាលនាក្រុងប៉ារីស។

ក្នុងកិច្ចពិភាក្សានាឱកាសនេះ អង្គប្រជុំបានផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការដែលកម្ពុជា និងបារាំងអាចរៀបចំឡើងក្នុងក្របខណ្ឌវិស័យថាមពល។ពិសេសជាងនេះអគ្គិសនីបារាំងបានលើកឡើងអំពីចំណាប់អារម្មណ៍របស់ខ្លួនលើវិស័យពាក់ព័ន្ធនឹងការផ្គត់ផ្គង់ថាមពល និងថាមពលស្អាតនៅកម្ពុជា ដែលស្នើសុំឱ្យមានការណែនាំពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអំពីបច្ចុប្បន្នភាពបរិយាកាសលើវិស័យនេះផងដែរ។

នាវេលារសៀលថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ប្រតិភូសមាគមឧកញ៉ាកម្ពុជា បានបន្តអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញជួបពិភាក្សាការងារជាមួយលោក Philippe Delleur អនុប្រធានជាន់ខ្ពស់ផ្នែកកិច្ចការសាធារណៈនៃក្រុមហ៊ុន Alstom Group ដែលជាក្រុមហ៊ុនវិនិយោគលើវិស័យដឹកជញ្ជូន ពិសេសការដឹកជញ្ជូនតាមផ្លូវដែកដ៏ធំជាងគេនៅក្នុងប្រទេសបារាំង និងក្នុងទ្វីបអឺរ៉ុប។ តាមរយៈជំនួបនេះ ក្រុមហ៊ុនបានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់ប្រតិភូកម្ពុជា ព្រមទាំងបង្ហាញសុទិដ្ឋិនិយមក្នុងការពិនិត្យលទ្ធភាពចូលរួមជំរុញហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជាឱ្យស្របតាមបច្ចេកទេសជាសកល ដែលអាចជំរុញភាពទាន់ពេលវេលា និងកាត់បន្ថយការបំពុលបរិស្ថានជាដើម។

ក្នុងកិច្ចពិភាក្សានេះដែរឯកឧត្តមឧបនាយករដ្ឋមន្ត្រីជម្រាបជូនអំពីកិច្ចការងារដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តលើការធ្វើឱ្យប្រសើរឡើង និងសិក្សាសមិទ្ធិលទ្ធភាពលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកនៅកម្ពុជា មានជាអាទិ៍ ការធ្វើឱ្យប្រសើរឡើងផ្លូវដែកភាគខាងជើង ភ្នំពេញ-ប៉ោយប៉ែត, ការធ្វើឱ្យប្រសើរឡើងផ្លូវដែកភាគខាងត្បូង ភ្នំពេញ-ព្រះសីហនុ,គម្រោងសិក្សាសមិទ្ធិលទ្ធភាពរថភ្លើងធុនស្រាលតភ្ជាប់ពីអាកាសយានដ្ឋានសៀមរាបក្រុងសៀមរាប និងគម្រោងសិក្សាសមិទ្ធិលទ្ធភាពប្រភេទរថភ្លើងក្រោមដី, AGT, Monorail និង Metro ជាដើម។

ក្នុងអំឡុងពេលកំពុងបំពេញបេសកកម្មនៅក្នុងប្រទេសបារាំងនេះដែរគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានបន្តអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អញ្ជើញជួបពិភាក្សាការងារជាមួយលោក Jonathan TURGY អ្នកគ្រប់គ្រងការដេញថ្លៃ និងអភិវឌ្ឍន៍អាជីវកម្ម នៃក្រុមហ៊ុន Systra និងលោក Marc Giroussens អ្នកគ្រប់គ្រងទូទៅ នៃក្រុមហ៊ុន Artelia ក្នុងកិច្ចប្រជុំរួមគ្នា នៅទីស្នាក់ការកណ្តាលក្រុមហ៊ុន Alstom Group កាលពីរសៀលថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤។

របៀបវារៈក្នុងកិច្ចប្រជុំនាឱកាសនេះបានផ្តោតការពិភាក្សាផ្លាស់ប្តូរយោបល់លើបរិយាកាសវិនិយោគនិងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជាពិសេសក្នុងប្រព័ន្ធផ្លូវដែកដើម្បីចូលរួមគាំទ្រដល់ភាពរីកចម្រើនរបស់សង្គមសេដ្ឋកិច្ចកម្ពុជា។

សូមបញ្ជាក់ថាក្រុមហ៊ុនSystraគឺជាក្រុមហ៊ុនវិស្វកម្មដែលផ្តល់សេវាកម្មប្រឹក្សាលើការដឹកជញ្ជូនសាធារណៈ និងការរចនាវិស្វកម្មនិងគ្រប់គ្រងគម្រោងដែលទាក់ទងនឹងប្រព័ន្ធផ្លូវដែកនិងប្រព័ន្ធដឹកជញ្ជូនធំៗដូចជារថភ្លើងក្រោមដី ផ្លូវរថភ្លើងធុនស្រាល ផ្លូវរថភ្លើង ផ្លូវរថភ្លើងល្បឿនលឿន និងប្រព័ន្ធដឹកជញ្ជូនរហ័សជាដើម។ ចំពោះក្រុមហ៊ុន Artelia គឺជាក្រុមហ៊ុនវិស្វកម្មអន្តរជាតិរបស់បារាំង ដែលផ្តល់សេវាកម្មលើការគ្រប់គ្រងគម្រោង និងប្រឹក្សាយោបល់មានឯកទេសលើផ្នែកសំណង់ ហេដ្ឋារចនាសម្ព័ន្ធ ទឹក ថាមពល និងគម្រោងបរិស្ថានផងដែរ












## ជំនួបរវាងឯកឧត្តម ស៊ុន ចាន់ថុល និងប្រធានសហព័ន្ធនិយោជកបារាំងអន្តរជាតិ (MEDEF International) ព្រមទាំងការរៀបចំជំនួបផ្គូរផ្គងធុរកិច្ចរវាងក្រុមហ៊ុនកម្ពុជា-បារាំង ចំនួន១០ក្រុមហ៊ុន

នារសៀលថ្ងៃពុធ ទី៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈប្រតិភូកម្ពុជា បានអញ្ជើញជួបពិភាក្សាការងារជាមួយលោក François Corbin អនុប្រធានសហព័ន្ធនិយោជកបារាំងអន្តរជាតិ (MEDEF International) និងរៀបចំជំនួបផ្គូរផ្គងធុរកិច្ចរវាងក្រុមហ៊ុនកម្ពុជា-បារាំង ចំនួន១០ក្រុមហ៊ុន។

ជំនួបនាឱកាសនេះត្រូវបានរៀបចុះឡើងក្នុងគោលបំណងដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់លើកិច្ចសហការនានារវាងកម្ពុជានិងបារាំងលើការងារបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជំនាញរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងគោលដៅបង្កើនអ្នកមានជំនាញក្នុងស្រុកឱ្យបានជាអតិបរិមា ចូលរួមការប្រកួតប្រជែងក្នុងផលិតកម្មការងារ។ ក្នុងកិច្ចប្រជុំនេះដែរ ក្រុមហ៊ុនរបស់ប្រទេសបារាំងក៏បានស្វែងយល់អំពីបរិយាកាស និងសក្តានុពលវិនិយោគនៅកម្ពុជា ពិសេសផ្តោតលើវិស័យថាមពលកកើតឡើងវិញ និងការលើកកម្ពស់ការតភ្ជាប់នៅទូទាំងប្រទេស។ បន្ថែមពីនេះ អង្គប្រជុំក៏បានរៀបចំផ្គូផ្គងវិនិយោគិនបារាំង និងកម្ពុជា ដែលមានសក្តានុពលលើវិស័យផ្សេងៗគ្នា។

ឆ្លៀតក្នុងឱកាសនៃកិច្ចប្រជុំនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានរំលេចជូនដល់វិនិយោគិនអំពីស្ថានភាពសុខសន្តិភាព ស្ថិរភាពរបស់កម្ពុជា និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់ទម្រង់ ដែលបាននិងកំពុងផ្តល់លទ្ធភាពជូនវិនិយោគិនរបស់ប្រទេសបារាំងកាន់តែមានភាពងាយស្រួលក្នុងការបណ្តាក់ទុនវិនិយោគបន្ថែមទៀតផងដែរ។
















## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដឹកនាំគណៈប្រតិភូកម្ពុជា បំពេញទស្សនកិច្ចនៅសាធារណរដ្ឋឆែក

នារសៀលថ្ងៃព្រហស្បតិ៍ ទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានចាប់ផ្តើមបេសកកម្មទាក់ទាញនិងជំរុញវិនិយោគនៅសាធារណរដ្ឋឆែកដោយបានជួបពិភាក្សាការងារជាមួយលោក Jiří Kozák អនុរដ្ឋមន្ត្រីការបរទេស នៃក្រសួងការបរទេសនៃសាធារណរដ្ឋឆែកផងដែរ។

ក្រោមការទទួលយ៉ាងកក់ក្តៅពីក្រសួងការបរទេសនៃសាធារណរដ្ឋឆែក ក្នុងកិច្ចពិភាក្សានាឱកាសនេះភាគីទាំងពីរបានបង្ហាញចំណាប់អារម្មណ៍អំពីទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការងារនានាសម្រាប់ពង្រឹងទំនាក់ទំនងឱ្យកាន់តែស៊ីជម្រៅ ពិសេសតាមរយៈកិច្ចការងារវិនិយោគឯកជន។ តាមរយៈជំនួបនេះក៏មានការលើកឡើងអំពីក្រុមហ៊ុនចំនួន៤របស់ឆែក ដែលកំពុងមានចំណាប់អារម្មណ៍នឹងពិនិត្យលទ្ធភាពបណ្តាក់ទុនវិនិយោគនៅកម្ពុជា លើវិស័យមានជាអាទិ៍ការផលិតឧបករណ៍វេជ្ជសាស្ត្រ ការសិក្សាស្រាវជ្រាវ និងការផលិតទឹកស្អាតជាដើម។




## វេទិកាធុរកិច្ចកម្ពុជា-ឆែក នៅទីស្តីការក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មនៃសាធារណរដ្ឋឆែក ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីបរិយាកាសវិនិយោគនៅកម្ពុជា

ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈប្រតិភូកម្ពុជា ដោយមានការគាំទ្រពីសហភាពអឺរ៉ុប បានរៀបចំវេទិកាធុរកិច្ចជាមួយសហព័ន្ធឧស្សាហកម្មឆែក នៅទីស្តីការក្រសួងពាណិជ្ជកម្មនិងឧស្សាហកម្មនៃសាធារណរដ្ឋឆែកដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីបរិយាកាសវិនិយោគនៅកម្ពុជា។

កម្មវិធីនាឱកាសនេះបានបើកឱកាសឱ្យភាគីទាំងពីរកម្ពុជា-ឆែកអាចពិភាក្សាផ្លាស់ប្តូរមតិយោបល់ទៅវិញទៅមកអំពីស្ថានភាពពាណិជ្ជកម្មនិងការវិនិយោគរវាងគ្នា ពិសេសកម្ពុជាបង្ហាញអំពីកាលានុវត្តភាពថ្មីៗជូនវិនិយោគិនឆែកផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ដល់កិច្ចការងារវិនិយោគ រួមមានការដាក់ឱ្យអនុវត្តច្បាប់ស្តីពីវិនិយោគដែលគ្មានការរឹតបន្តឹងសម្រាប់វិនិយោគិនបរទេស ពិសេសគឺមានរៀបចំនូវគំនិតផ្តួចផ្តើមនានា ក៏ដូចជាបង្កើតឱ្យមានក្រុមការងារបច្ចេកទេសចំនួន១៦ ពាក់ព័ន្ធនឹងវិស័យឯកជន និងរដ្ឋាភិបាល ដើម្បីគាំទ្រដល់ប្រក្រតីភាពរបស់វិនិយោគិនដែលកំពុងបណ្តាក់ទុននិងមានបំណងបណ្តាក់ទុនវិនិយោគនៅកម្ពុជា។ជាមួយនឹងស្ថានភាពសុខសន្តិភាពពេញលេញ កំណើនសេដ្ឋកិច្ច មានកម្លាំងពលកម្មវ័យក្មេង និងទំនាក់ទំនងពាណិជ្ជកម្មល្អប្រសើរជាមួយប្រទេសនានា រួមមានប្រទេសជប៉ុន កូរ៉េ សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ដែលនេះនឹងបើកទីផ្សារកាន់តែទូលាយដល់វិនិយោគិន។









**ជំនួបពិភាក្សាតុមូលរវាងគណៈប្រតិភូកម្ពុជា ជាមួយ អ្នកតំណាងសមាគមធុរកិច្ច និងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ និងទស្សនកិច្ចក្រុមហ៊ុន BTL Medical Technologies**

ក្នុងឱកាសបំពេញបេសកកម្មនៅទីក្រុងប្រាក នៃសាធារណរដ្ឋឆែក គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានបន្តចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបពិភាក្សាតុមូលជាមួយអ្នកតំណាងសមាគមធុរកិច្ច និងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ នៅទីស្តីការក្រសួងការបរទេសនៃសាធារណរដ្ឋឆែកកាលពីរសៀលថ្ងៃព្រហស្បត្តិ ទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះក្រសួងការបរទេសនៃសាធារណរដ្ឋឆែកដែលបានទទួលគណៈប្រតិភូកម្ពុជាបានប្រកបដោយភាពកក់ក្តៅ។ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានជម្រាបជូនអំពីធនធានមនុស្សកម្ពុជា ដែលមានយុវជនវ័យក្មេងច្រើនជាងប្រទេសផ្សេងទៀតក្នុងតំបន់នឹងអាចចូលរួមយ៉ាងពេញទំហឹងក្នុងផលិតកម្មការងារ។រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ស្តីពីវិនិយោគកាលពីឆ្នាំ២០២១ បើកលទ្ធភាពយ៉ាងល្អប្រសើរជូនវិនិយោគិនអាចទទួលបានការលើកទឹកចិត្តលើគម្រោងមានសក្តានុពលមួយចំនួនក្រោមការសម្របសម្រួលពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាល។ យន្តការរដ្ឋាភិបាល និងវិស័យឯកជន ព្រមទាំងយន្តការតាមដាន និងសម្របសម្រួលនានាត្រូវបានដាក់ចេញ ដើម្បីថែទាំវិនិយោគិនដែលបាននិងកំពុងបណ្តាក់ទុននៅកម្ពុជា។នាពេលឆាប់ៗខាងមុខនេះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគ្រោងនឹងដាក់ចេញជាសាធារណៈនូវប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (ប្រព័ន្ធ cdcIPM) ដែលនឹងចូលរួមធានាតម្លាភាព ប្រសិទ្ធភាព និងផ្តល់ងាយស្រួលដល់កិច្ចការងារវិនិយោគជូនគ្រប់ភាគីពាក់ព័ន្ធ។

កម្ពុជាមានចក្ខុវិស័យក្នុងការប្រែក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ហេតុនេះក្នុងនាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកទឹកចិត្តទៅកាន់សាធារណរដ្ឋឆែក និងតាមរយៈក្រសួងការបរទេសផ្ទាល់ ចូលរួមជួយជំរុញឱ្យវិនិយោគិនឆែកពិនិត្យលទ្ធភាពបណ្តាក់ទុនវិនិយោគនៅកម្ពុជា ពិសេសលើវិស័យអេឡិចត្រូនិក អាហារ និងទេសចរណ៍ជាដើម។

បន្ទាប់មក នាពីព្រឹកថ្ងៃសុក្រ ទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈប្រតិភូកម្ពុជាដែលរួមមានពីក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន បានអញ្ជើញទស្សនកិច្ចក្រុមហ៊ុនBTLMedicalTechnologiesដែលជាក្រុមហ៊ុនឈានមុខគេរបស់សាធារណរដ្ឋឆែកនិងមានប្រតិបត្តិការលើផលិតផលឧបករណ៍បច្ចេកវិទ្យាវេជ្ជសាស្ត្រ។

តាមរយៈកិច្ចប្រជុំនាឱកាសនេះ ក្រុមហ៊ុនបានធ្វើបទបង្ហាញជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងគណៈប្រតិភូកម្ពុជាអំពីផលប័ត្រផលិតកម្មបច្ចេកវិទ្យាកាលានុវត្តភាពវិនិយោគរបស់ខ្លួនប្រមាណជាង៣០ឆ្នាំក្នុងវិស័យវេជ្ជសាស្ត្រ និងពិភាក្សាអំពីឱកាសវិនិយោគនៅកម្ពុជាផងដែរ។ឆ្លៀតក្នុងឱកាសនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានលើកទឹកចិត្តឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាពជ្រើសរើសការបណ្តាក់ទុននៅកម្ពុជាដោយហេតុថាក្រៅអំពីសក្តានុពលសំខាន់ៗជាច្រើន កម្ពុជាក៏ទទួលបានប្រព័ន្ធអនុគ្រោះពន្ធ EBA សម្រាប់ការនាំចេញទៅកាន់ទីផ្សាររបស់សហភាពអឺរ៉ុបផងដែរ។












## លោកជំទាវឧកញ៉ា កង លាប ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងបានបន្តថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៧១ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា



នារសៀលថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ លោកជំទាវឧកញ៉ា កង លាប សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងបានបន្តថ្វាយកម្រងផ្កាគោរព**ព្រះវិញ្ញាណក្ខន្ធព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** នៅមណ្ឌបព្រះបរមរូប ខាងកើតវិមានឯករាជ្យក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៧១ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា។

នេះជាការរំលឹកនឹកដល់គុណូបការៈ និងវីរភាពដ៏ធំធេងរបស់ព្រះករុណាព្រះបរមរតនកោដ្ឋដែលបានបំពេញព្រះរាជបូជនីយកិច្ចនិងបូជាអស់កម្លាំងព្រះកាយពលព្រះបញ្ញាញាណក្នុងការដណ្តើមឯករាជ្យពីប្រទេសបារាំងព្រមទាំងពលិកម្មប្រកបដោយវីរភាពដ៏អង់អាចរបស់យុទ្ធជនក៏ដូចជាប្រជាពលរដ្ឋខ្មែរប្រុសស្រីប្រកបដោយសាមគ្គីភាពក្នុងការដណ្តើមបានមកវិញនូវសិទ្ធិសេរីភាព និងភាពជាម្ចាស់ទឹកដីរបស់ប្រជាជាតិកម្ពុជានេះផងដែរ។

ជាមួយគ្នានេះ នាព្រឹកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ក៏ចូលរួមក្នុងព្រះរាជពិធីអុជភ្លើងជ័យអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទរបស់ព្រះរាជាណាចក្រកម្ពុជា( ៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៤ ) ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា បានរំលឹកឲ្យឃើញពីព្រះរាជបេសកកម្មដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែររបស់**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិ ព្រះបរមរតនកោដ្ឋ** ដែលព្រះអង្គបានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុតធ្វើការតស៊ូក្នុងក្របខណ្ឌនៃព្រះរាជបូជនីយកិច្ចដើម្បីទាមទារឯករាជ្យដ៏ពិតប្រាកដនៅកម្ពុជា។



















## លោកអ្នកឧកញ៉ា លី ហួរ ចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នា រវាងមន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ និងសមាគមឧកញ៉ាកម្ពុជា




នាព្រឹកថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូប បានអញ្ជើញចូលរួមជាអធិបតី និងជាភ្ញៀវកិត្តិយសក្នុង " ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញនិងសមាគមឧកញ៉ាកម្ពុជា"ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់នូវអត្ថប្រយោជន៍ពាក់ព័ន្ធនឹងការផ្តល់សេវាពិនិត្យសុខភាព និងព្យាបាលជំងឺនានា ប្រកបដោយគុណភាពខ្ពស់តាមស្តង់ដាអន្តរជាតិជូនដល់សមាជិកទាំងអស់ នៃសមាគមឧកញ៉ាកម្ពុជា ព្រមទាំងក្រុមគ្រួសារ។

លោកវេជ្ជបណ្ឌិត Attapoom Susupaus នាយកមន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ បានថ្លែងថា នេះជាកិត្តិយសដ៏ធំធេង ដែលលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបសុទ្ធសឹងជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីប្រកបដោយអត្ថន័យនេះ ខណៈដែលលោកមានក្តីរំពឹងថា តាមរយៈអនុស្សរណៈនេះ ភាគីទាំងពីរនឹងទទួលបាននូវអត្ថប្រយោជន៍ទៅវិញទៅមកជាពិសេសលើការថែទាំសុខុមាលភាព រួមមាន ការផ្តល់ជូននូវកញ្ចប់ Prime+ និង Prime Packages ដែលជាជម្រើសល្អបំផុតមួយ ដោយហេតុថា មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ មានបំពាក់ដោយបរិក្ខារទំនើបៗប្រកបដោយបច្ចេកវិទ្យាខ្ពស់ ដូចជា ម៉ាស៊ីន the state-of-the-art MRI 3 Tesla scanner ជាដើម ព្រមទាំងមានវេជ្ជបណ្ឌិត និងគ្រូពេទ្យដែលមានជំនាញឯកទេសច្បាស់លាស់ក្នុងការពិនិត្យ តាមដាន និងព្យាបាលជំងឺដោយទទួលបានទំនុកចិត្តពីអតិថិជនជាច្រើននៅក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះទៅលើផ្នែកសង្គ្រោះបន្ទាន់ ជំងឺបេះដូង ផ្នែកឆ្អឹង និងការថែទាំមាតានិងទារកផងដែរ។

ទន្ទឹមនឹងនេះ លោកអ្នកឧកញ៉ា លី ហួរ បានថ្លែងការកោតសសើរចំពោះថ្នាក់ដឹកនាំ គ្រូពេទ្យ និងបុគ្គលិកទាំងអស់របស់មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយកម្លាំងចិត្ត ដោយមានយកចិត្តទុកដាក់ជាទីបំផុតក្នុងការផ្តល់និងបម្រើសេវាសុខាភិបាលកម្រិតស្តង់ដាអន្តរជាតិព្រមទាំងគុណភាពខ្ពស់ដល់អ្នកជំងឺជាតិ និងអន្តរជាតិនៅកម្ពុជា។

លោកអ្នកឧកញ៉ាបានថ្លែងបន្ថែមថា៖ " ការចុះអនុស្សរណៈយោគយល់គ្នានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សមាជិករបស់សមាគមឧកញ៉ាកម្ពុជាក៏ដូចជាការផ្តល់ជូននូវកាតបញ្ចុះតម្លៃទៅតាមកម្រិតនៃប្រភេទសេវាកម្មនីមួយៗ។ ដូច្នេះ ខ្ញុំមានកិត្តិយសសូមលើកទឹកចិត្ត និងសូមអញ្ជើញសមាជិកដែលបានអញ្ជើញចូលរួម និងមិនបានអញ្ជើញចូលរួមនៅថ្ងៃនេះក្តីអាចសាកល្បងប្រើប្រាស់សេវាកម្មណាមួយរបស់មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញដែលមានជាអាទិ៍ ការគ្រោះយោបល់ ការពិនិត្យសុខភាព ឬការព្យាបាលជំងឺនានាជាដើមចាប់ពីថ្ងៃនេះតទៅ។"

សូមជម្រាបជូនថា មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ គឺជាមន្ទីរពេទ្យក្នុងស្រុកមួយដែលបាននិងកំពុងប្រើប្រាស់ឧបករណ៍ ក៏ដូចជាបរិក្ខារពេទ្យទំនើបៗទាន់សម័យ ដែលមានគុណភាពស្តង់ដាអន្តរជាតិ សេវាកម្មសម្បូរបែប និងមានតម្លៃសមរម្យ ជាមួយនឹងគ្រូពេទ្យដែលមានជំនាញ និងមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងវិស័យសុខាភិបាល។

អាស្រ័យហេតុនេះប្រជាពលរដ្ឋកម្ពុជាអាចធ្វើការកាត់បន្ថយចំណាយផ្សេងៗព្រមទាំងថវិកានិងពេលវេលាក្នុងការចេញទៅព្យាបាលនៅឯក្រៅប្រទេសដែលទាំងអស់នេះគឺជាការគិតគូរមួយរបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យជាពិសេសឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ក្នុងការផ្តល់សេវាកម្មដែលមានជម្រើសច្រើន និងគុណភាពសុខាភិបាលកាន់តែប្រសើរដល់ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន។















មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ និង




អបអរសាទរ
ពិធីចុះហត្ថលេខា លើអនុស្សរណៈយោគយល់គ្នា
រវាង
មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ និង សមាគមឧកញ៉ាកម្ពុជា
ROYAL PHNOM PENH HOSPITAL


អបអរសាទរ
ពិធីចុះហត្ថលេខា លើអនុស្សរណៈយោគយល់គ្នា
រវាង
ROYAL PHNOM PENH HOSPITAL


ពិធីចុះហត្ថលេខា លើអនុស្សរណៈយោគយល់គ្នា
រវាង
ROYAL PHNOM PENH HOSPITAL





## ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមជាអធិបតី និងជាភ្ញៀវកិត្តិយសក្នុងពិធីជប់លៀងអបអរគម្រប់ខួប ១០ឆ្នាំ របស់មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ

នាល្ងាចថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូប បានអញ្ជើញចូលរួមជាអធិបតី និងជាភ្ញៀវកិត្តិយសក្នុង " ពិធីជប់លៀងអបអរគម្រប់ខួប ១០ឆ្នាំ របស់មន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ " ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ ហ្គាឌិន ស៊ីធី។

គួររំលឹកថាសមាគមឧកញ៉ាកម្ពុជាទើបតែបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ក្នុងគោលបំណងផ្តល់នូវអត្ថប្រយោជន៍ ពាក់ព័ន្ធនឹងការផ្តល់សេវាពិនិត្យសុខភាព និងព្យាបាលជំងឺនានាប្រកបដោយគុណភាពខ្ពស់តាមស្តង់ដាអន្តរជាតិជូនដល់សមាជិកទាំងអស់ នៃសមាគមឧកញ៉ាកម្ពុជា ព្រមទាំងក្រុមគ្រួសារតាមរយៈការផ្តល់ជូននូវកញ្ចប់ Prime+ និង Prime Packages ផងដែរ។

សូមបញ្ជាក់ថាមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញគឺជាមន្ទីរពេទ្យក្នុងស្រុកមួយដែលបាននិងកំពុងប្រើប្រាស់ឧបករណ៍ក៏ដូចជាបរិក្ខារពេទ្យទំនើបៗទាន់សម័យ ដែលមានគុណភាពស្តង់ដាអន្តរជាតិ សេវាកម្មសម្បូរបែប និងមានតម្លៃសមរម្យជាមួយនឹងគ្រូពេទ្យដែលមានជំនាញនិងមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងវិស័យសុខាភិបាល។អាស្រ័យហេតុនេះប្រជាពលរដ្ឋកម្ពុជាអាចធ្វើការកាត់បន្ថយចំណាយផ្សេងៗព្រមទាំងថវិកានិងពេលវេលាក្នុងការចេញទៅព្យាបាលនៅឯក្រៅប្រទេស ដែលទាំងអស់នេះគឺជាការគិតគូរមួយរបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យ ជាពិសេស ឆ្លើយតបទៅនឹងយុទ្ធសាស្រ្តរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ក្នុងការផ្តល់សេវាកម្មដែលមានជម្រើសច្រើននិងគុណភាពសុខាភិបាលកាន់តែប្រសើរដល់ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន។















YEAR ANNIVERSARY


## សមាគមឧកញ៉ាកម្ពុជា សហការជាមួយ សមាគមជប៉ុន-កម្ពុជា បានរៀបចំពិធីបើក “ជំនួបផ្គូផ្គងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងសមាគមជប៉ុន-កម្ពុជា ២០២៤” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នាព្រឹកថ្ងៃអង្គារ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមឧកញ៉ាកម្ពុជា សហការជាមួយ សមាគមជប៉ុន-កម្ពុជា បានរៀបចំពិធីបើក «ជំនួបផ្គូផ្គងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងសមាគមជប៉ុន-កម្ពុជា ២០២៤» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម TAKAHASHI Fumiaki ប្រធានសមាគមជប៉ុន-កម្ពុជា និងជាអតីតអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអ្នកឧកញ៉ា ឧកញ៉ា ជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា និងធុរជនជប៉ុន-កម្ពុជាដែលមានចំនួនសរុបប្រមាណ ១២០រូប។

ក្នុងឱកាសនេះដែរ ឯកឧត្តម TAKAHASHI Fumiaki បានថ្លែងថា ជំនួបផ្គូផ្គងធុរកិច្ចនេះ បានធ្វើឡើងក្រោយកិច្ចពិភាក្សាការងាររវាងភាគីសមាគមឧកញ៉ាកម្ពុជា និងសមាគមជប៉ុន-កម្ពុជា ក្រោមវត្តមានរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល នៅទីក្រុងតូក្យូ កាលពីខែឧសភា ឆ្នាំ២០២៤ កន្លងទៅថ្មីៗនេះ ក្នុងគោលបំណងផ្តល់នូវការធ្វើបច្ចុប្បន្នភាពនៃស្ថានភាពវិនិយោគនៅកម្ពុជា និងផ្តល់នូវកាលានុវត្តភាពក្នុងការជ្រើសរើសដៃគូសម្រាប់ធ្វើជំនួបផ្គូផ្គងទៅតាមវិស័យនៃអាជីវកម្មរបស់ខ្លួន។ ដូច្នេះ ឯកឧត្តមមានសុទិដ្ឋិនិយមថា តាមរយៈជំនួបនាថ្ងៃនេះ ភាគីទាំងពីរនឹងបានភ្ជាប់ទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកប្រកបដោយទំនុកចិត្ត។

លោកជំទាវអ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា និងជាអនុប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ បានថ្លែងអំណរគុណចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល និងឯកឧត្តម TAKAHASHI Fumiaki ព្រមទាំងធុរជនជប៉ុនដែលមានវត្តមាននៅក្នុងព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ និងជាកិច្ចសហការលើកដំបូងរវាងសមាគមទាំងពីរ ដែលសមាគមឧកញ៉ាកម្ពុជាស្ថិតនៅក្រោមអភិបាលកិច្ចផ្នែកបច្ចេកទេសរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកិច្ចការធុរកិច្ច និងការវិនិយោគផងដែរ។










លោកជំទាវក៏បានជម្រាបជូនអង្គពិធីទាំងមូលនូវចក្ខុវិស័យ និងបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជា ដែលកំពុងរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា សំដៅចូលរួមកសាង និងអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ ជាពិសេស សកម្មភាពសង្គមកិច្ចនិងមនុស្សធម៌ ដើម្បីធានាឱ្យបាននូវភាពសុខសាន្ត និងភាពរីកចម្រើនដល់ប្រជាជនកម្ពុជា ខណៈដែលសមាគមឧកញ៉ាកម្ពុជា គឺជាបណ្តុំធុរជនមកពីចម្រុះវិស័យក្នុងប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាហើយរហូតមកដល់ពេលបច្ចុប្បន្ននេះមានសមាជិកសរុប ៤២០ រូប ដែលកំពុងគ្រប់គ្រងក្រុមហ៊ុន និងសហគ្រាសរហូតដល់ជាង ៨០០ដោយបង្កើតការងារច្រើនជាង៥០០.០០០កន្លែងដល់ប្រជាជនកម្ពុជានៅទូទាំងប្រទេស។លោកជំទាវមានទំនុកចិត្តថា ជំនួបផ្គូផ្គងធុរកិច្ចថ្ងៃនេះ ពិតជាផ្តល់អត្ថប្រយោជន៍ បង្កើនភាពស្និទ្ធស្នាល និងពង្រឹងទំនុកចិត្តរវាងធុរជននៃប្រទេសទាំងពីរសម្រាប់កិច្ចសហប្រតិបត្តិការធុរកិច្ច និងវិនិយោគឱ្យលេចចេញជារូបរាងឡើងនាពេលខាងមុខ។

ទន្ទឹមនឹងនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បានមានប្រសាសន៍កោតសរសើរចំពោះសមាគមឧកញ៉ាកម្ពុជា និងសមាគមជប៉ុន-កម្ពុជា ដែលបានបំពេញបេសកកម្មរបស់ខ្លួនចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាដែលមាន សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជាប្រមុខដឹកនាំរាជរដ្ឋាភិបាល ជាពិសេសក្នុងសកម្មភាពជំរុញនិងការកៀរគរវិនិយោគិនឱ្យមកបណ្តាក់ទុននៅកម្ពុជា។ឯកឧត្តមបានគូសបញ្ជាក់ថាឯកឧត្តមមានក្តីរីករាយដែលបានក្លាយជាអ្នកផ្សារភ្ជាប់ទំនាក់ទំនងរវាងសមាគមទាំងពីរតាមរយៈបេសកកម្មគោះទ្វារវិនិយោគនៅឯប្រទេសជប៉ុនកាលពីខែឧសភា ឆ្នាំ២០២៤កន្លងទៅថ្មីៗនេះរហូតលេចចេញនូវការរៀបចំកម្មវិធីផ្គូផ្គងធុរកិច្ចនាថ្ងៃនេះ។



ឯកឧត្តមក៏បានលើកទឹកចិត្តនិងអំពាវនាវឱ្យវិនិយោគិនជប៉ុន និងវិនិយោគិនកម្ពុជាដែលមានវត្តមាននៅថ្ងៃនេះ ចាប់ដៃគ្នាសិក្សាពិនិត្យលទ្ធភាពជំរុញកិច្ចសហការធុរកិច្ច ក៏ដូចជាស្វែងយល់ឱ្យកាន់តែច្បាស់នូវកាលានុវត្តភាពវិនិយោគរបស់កម្ពុជាខណៈដែលគម្រោងវិនិយោគជប៉ុននៅកម្ពុជាមានការថយចុះបើប្រៀបធៀបទៅនឹងរយៈពេលមុនការរីករាលដាលនៃជំងឺកូវីដ-១៩។ឯកឧត្តមបានសង្កត់ធ្ងន់ថាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលលើការងារវិនិយោគ បានបន្តខិតខំជំរុញការកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគតាមរយៈការជំរុញផ្សព្វផ្សាយនូវច្បាប់ស្តីពីវិនិយោគការគោះទ្វារវិនិយោគក្រៅប្រទេសព្រមទាំងការសម្រួលនិងធ្វើសាមញ្ញកម្មនីតិវិធីពាក់ព័ន្ធនានាជាពិសេសការធ្វើឌីជីថលភាវូបនីយកម្មសម្រាប់ការផ្តល់សេវាសាធារណៈជាដើម ស្របពេលដែលកម្ពុជាមានឧត្តមភាពប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគយ៉ាងសម្បូរបែប មានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថេរភាព មានសេដ្ឋកិច្ចបើកចំហរបំផុត កម្ពុជាក៏មានគម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រសំខាន់ៗដូចជាផ្លូវល្បឿនលឿនដែលកំពុងសាងសង់ និងគ្រោងសាងសង់នាពេលខាងមុខ គម្រោងព្រែកជីកហ្វូណនតេជោ គម្រោងពង្រីកសមត្ថភាពកំពង់ផែទឹកជ្រៅនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុនិងគម្រោងសាងសង់អាកាសយានដ្ឋានថ្មីជាដើមជាពិសេសមានសុខសន្តិភាពដែលធានាដល់ការបណ្តាក់ទុនរយៈពេលវែងនិងស្ថិតនៅក្នុងទីតាំងយុទ្ធសាស្ត្រដែលស័ក្តិសមជាមជ្ឈមណ្ឌលប្រមូលផ្តុំផលិតកម្មសម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់និងជាច្រកចូលទៅកាន់ទីផ្សារធំៗដែលមានមូលដ្ឋានអ្នកប្រើប្រាស់ច្រើន។

សូមបញ្ជាក់ថានេះជាលើកទីពីរហើយដែលសមាគមឧកញ៉ាកម្ពុជាបានរៀបចំនូវជំនួបធុរកិច្ចជាមួយភាគីដៃគូជាតិ និងអន្តរជាតិ ដោយកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ មានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាតំណាងស្ថានទូតនានារួមទាំងអ្នកឧកញ៉ាឧកញ៉ានិងធុរជនក្នុងស្រុកនិងក្រៅប្រទេសប្រមាណជា ៤០០រូប។






















## អ្នកឧកញ៉ា សៀ ឬទ្ធី តំណាងសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមជាកិត្តិយស និងថ្លែងសុន្ទរកថាចំណាប់អារម្មណ៍ចូលរួមក្នុង “ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (CDC Investment Project Management System ហៅកាត់ថា ប្រព័ន្ធ cdcIPM) ដំណាក់កាលទី១”

នាព្រឹកថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ អ្នកឧកញ៉ា សៀ ឬទ្ធី តំណាងសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមជាកិត្តិយស និងថ្លែងសុន្ទរកថាចំណាប់អារម្មណ៍ ក្នុង “ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (CDC Investment Project Management System ហៅកាត់ថា ប្រព័ន្ធ cdcIPM) ដំណាក់កាលទី១” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ពិធីនេះបានប្រារព្ធធ្វើឡើងនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនសុី ភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី តំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលឯកឧត្តមឯកអគ្គរាជទូតឯកអគ្គរដ្ឋទូតតំណាងអង្គទូតអង្គការជាតិអន្តរជាតិវិស័យឯកជននិងបណ្ដាញសារព័ត៌មានសរុបប្រមាណជាង ៣៥០នាក់។

គោលបំណងនៃព្រឹត្តិការណ៍នេះ គឺដើម្បីផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធ cdcIPM ដែលត្រូវបានផ្ដួចផ្ដើមឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីផ្ដល់លទ្ធភាពឱ្យវិនិយោគិនដាក់ពាក្យដោយផ្ទាល់ពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដោយជួយសម្រួលកិច្ចវិនិយោគឱ្យកាន់តែមានភាពងាយស្រួល កាត់បន្ថយពេលវេលា ធានាបាននូវតម្លាភាព សុក្រឹតភាព និងប្រសិទ្ធភាព ព្រមទាំងចូលរួមកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល និងអនុវត្តនូវគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ លើសពីនេះ ប្រព័ន្ធ cdcIPM នេះ ក៏ជាការរួមចំណែកដល់ការជំរុញការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងចូលរួមគាំទ្រការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលបានកំណត់យកអាទិភាពគន្លឹះចំនួន ៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។


















ក្នុងឱកាសនេះផងដែរ អ្នកឧកញ៉ា សៀ ឬទ្ធី បានឡើងថ្លែងសុន្ទរកថាបង្ហាញចំណាប់អារម្មណ៍ ដោយសម្តែងការកោតសរសើរ និងចូលរួមអបអរសាទរគាំទ្រចំពោះកិច្ចប្រឹងប្រែងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការផ្តួចផ្តើម និងធ្វើឱ្យប្រព័ន្ធ cdcIPM លេចចេញជារូបរាងឡើងជាផ្លូវការនាថ្ងៃនេះ សម្រាប់ជាឧត្តមប្រយោជន៍ជាតិ។ អ្នកឧកញ៉ា បានលើកឡើងថាប្រព័ន្ធនេះនឹងផ្តល់ការគាំទ្រដល់កិច្ចវិនិយោគក្នុងកម្រិតតំបន់និងកម្រិតជាតិដោយវិនិយោគិនជាតិ និងអន្តរជាតិកាន់តែមានភាពងាយស្រួលក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីគម្រោងវិនិយោគរបស់ខ្លួន។ក្រៅពីនេះប្រព័ន្ធនេះក៏នឹងផ្តល់នូវអត្ថប្រយោជន៍ក្នុងរូបភាពជាច្រើនដូចជា១)តម្លាភាព៖កាត់បន្ថយភាពមិនប្រក្រតីនានារវាងវិនិយោគិន និងអ្នកផ្តល់សេវា ២) បណ្តុំទិន្នន័យ៖ ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងកិច្ចវិនិយោគ និងគម្រោងវិនិយោគនានា សម្រាប់វិនិយោគិនធ្វើការសម្រេចចិត្តដោយមិនចាំបាច់មកកាន់ទីតាំងផ្ទាល់៣)ទំនុកចិត្ត៖បង្ហាញអំពីតម្លៃពិតប្រាកដជាក់លាក់នៃសេវានានាក្នុងដំណើរការស្នើសុំចុះបញ្ជីគម្រោងវិនិយោគ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតផងដែរ។

ជាចុងបញ្ចប់ អ្នកឧកញ៉ា ក៏បានស្នើសុំឱ្យមានកន្លែងផ្តល់សេវាព័ត៌មាន សម្រាប់ឆ្លើយតបរាល់បញ្ហា ឬចម្ងល់នានាអំពីការប្រើប្រាស់ប្រព័ន្ធនេះហើយវិនិយោគិនផ្ទាល់ក៏ត្រូវពង្រឹងចំណេះដឹងបច្ចេកវិទ្យាដើម្បីងាយស្រួលប្រើប្រាស់ និងទាញប្រយោជន៍ពីប្រព័ន្ធខាងលើនេះ បើពុំដូច្នោះ ការបង្កើតប្រព័ន្ធនេះឡើងនឹងត្រូវទុកជាអសារបង់មិនខាន។

## លោកអ្នកឧកញ៉ា លី ហួរ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ជួបសំណេះសំណាលជាមួយ ប្រតិភូនៃសភាពាណិជ្ជកម្មកម្ពុជារដ្ឋកាលីហ្វ័រញ៉ា ដឹកនាំដោយលោក គីមឆា ហួត អគ្គកុងស៊ុលកិត្តិយស និងជាប្រធានការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាប្រចាំរដ្ឋកាលីហ្វ័រញ៉ា

នារសៀលថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមានរបស់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំក៏ដូចជា សមាជិកនៃសមាគមឧកញ៉ាកម្ពុជា បានទទួលជួបសំណេះសំណាលជាមួយប្រតិភូនៃសភាពាណិជ្ជកម្មកម្ពុជារដ្ឋកាលីហ្វ័រញ៉ា ដឹកនាំដោយលោក គីមឆា ហួត អគ្គកុងស៊ុលកិត្តិយស និងជាប្រធានការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាប្រចាំរដ្ឋកាលីហ្វ័រញ៉ា។

ជាកិច្ចចាប់ផ្តើម លោកអ្នកឧកញ៉ា លី ហួរ បានមានប្រសាសន៍ ស្វាគមន៍ចំពោះគណៈប្រតិភូទាំងអស់ដែលមានវត្តមានក្នុងជំនួបធុរកិច្ចជាលើកដំបូងរវាងស្ថាប័នទាំងពីរដែលជាការសំណេះសំណាលនិងជាកិច្ចចាប់ផ្តើមក្នុងការកសាងនូវទំនាក់ទំនងពាណិជ្ជកម្មជាមួយគ្នាទៅវិញទៅមក ខណៈដែលសមាគមឧកញ៉ាកម្ពុជាមានសមាជិកសុទ្ធសឹងតែជាពាណិជ្ជករ ជាវិនិយោគិនដែលកំពុងកាន់កាប់អាជីវកម្មលើពហុវិស័យនៅក្នុងប្រទេសកម្ពុជា និងមានសក្តានុពលនៅក្នុងការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេស សហរដ្ឋអាម៉េរិកតែម្តង។





ទន្ទឹមនឹងនេះ លោក គីមឆា ហួត បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ នៃសមាគមឧកញ៉ាកម្ពុជា ដែលបានអនុញ្ញាតឱ្យរូបលោកនិងប្រតិភូជាធុរជនមកពីសហរដ្ឋអាម៉េរិកបានចូលជួបសម្តែងការគួរសមនិងពិភាក្សាធុរកិច្ចដោយលោកមានសុទិដ្ឋិនិយមថានេះជាជំហានដ៏វិជ្ជមានក្នុងការពង្រីកទីផ្សារផលិតផលកម្ពុជាទៅកាន់សហរដ្ឋអាម៉េរិកដែលមានប្រជាជនខ្មែរកំពុងរស់នៅប្រមាណជាង៦សែននាក់ក្នុងនោះរដ្ឋកាលីហ្វ័រញ៉ាមានចំនួនច្រើនជាងគេពោលគឺជាង៣សែននាក់។ លោកបានបន្ថែមថា នាពេលបច្ចុប្បន្ន ផលិតផលកម្ពុជាកំពុងទទួលបានគាំទ្រខ្លាំងឡើងៗជាពិសេសកសិផល រួមមាន គ្រាប់ស្វាយចន្ទី អង្ករ និងដំណាប់ស្វាយ ជាដើម ព្រមទាំង ស្រាបៀរផងដែរ។ ហេតុនេះ ការជំរុញផលិតផលកម្ពុជាឆ្ពោះទៅកាន់ទីផ្សារអាម៉េរិកគឺជាគោលដៅមួយដែលលោកនិងសហការីកំពុងយកចិត្តទុកដាក់ដោយផ្តោតលើការផ្សព្វផ្សាយផលិតផលដែលមានគុណភាពខ្ពស់ពីប្រទេសកម្ពុជា រួមទាំងការពង្រីកទីផ្សារចូលទៅកាន់បណ្តាផ្សារទំនើបនានានៅក្នុងសហរដ្ឋអាម៉េរិកដើម្បីរួមចំណែកបង្កើតការងារក្នុងស្រុកនិងជាការផ្សព្វផ្សាយនូវផលិតផលកម្ពុជាលើឆាកអន្តរជាតិផងដែរ។

ជាមួយគ្នានេះលោកអគ្គកុងស៊ុលកិត្តិយស បានរំលឹកថាក្នុងកម្មវិធីពិព័រណ៍ពាណិជ្ជកម្មកម្ពុជានៅលើទឹកដីសហរដ្ឋអាម៉េរិកកាលពីឆ្នាំ២០២៣កន្លងទៅ មានការចូលរួមពីក្រុមហ៊ុន និងធុរជនពីកម្ពុជាប្រមាណជាជាង ៣០០នាក់ ដោយភាគច្រើនជាផលិតផលម្ហូបអាហារហើយសម្រាប់ឆ្នាំ២០២៥ខាងមុខលោកមានគម្រោងបង្កើនដល់៥០០នាក់ ជាមួយនឹងផលិតផលចម្រុះជាច្រើនប្រភេទសម្រាប់ដាក់តាំងបង្ហាញដល់អតិថិជន។ ជាងនេះទៅទៀត លោកបានបញ្ជាក់ថា លោកនឹងដឹកនាំសហការីជាច្រើនរូបទៀតចូលជួបពិភាក្សាការងារជាមួយសមាគមឧកញ៉ាកម្ពុជានាអំឡុងបេសកកម្មនាដើមឆ្នាំ២០២៥ដើម្បីស្វែងរកកាលានុវត្តភាពក្នុងការបង្កើតកិច្ចសហការធុរកិច្ចរវាងធុរជនអាម៉េរិកដែលមានបំណងវិនិយោគនៅកម្ពុជា ជាមួយនឹងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ដោយក្នុងនោះរួមមាន គម្រោងបង្កើតរោងចក្រផលិតដែកដើម្បីនាំចេញគួបផ្សំនឹងផលិតផលមួយចំនួនផ្សេងទៀត។

ក្នុងឱកាសនេះដែរ ប្រតិភូនៃស្ថាប័នទាំងពីរបានធ្វើបទបង្ហាញអំពីសមាសភាព និងអាជីវកម្មរបស់ខ្លួនទៅវិញទៅមកដើម្បីងាយស្រួលក្នុងការផ្គូផ្គងពាណិជ្ជកម្មនិងការចាប់ដៃគូជាមួយគ្នា ក្នុងនោះរួមមាន វិស័យបច្ចេកវិទ្យា កសិ-ឧស្សាហកម្ម ទេសចរណ៍ ដឹកជញ្ជូន សុខាភិបាល ច្បាប់និងពន្ធដារ និងវិស័យអប់រំជាដើម។

ជាកិច្ចបញ្ចប់ លោកអ្នកឧកញ៉ា លី ហួរ បានមានប្រសាសន៍ថា តាមរយៈសមាសភាពចូលរួមនៅថ្ងៃនេះ សង្កេតឃើញថាសុទ្ធសឹងតែជាធុរជនដែលមានទស្សនវិស័យនិងសក្តានុពលក្នុងការជំរុញការពង្រីកទីផ្សារផលិតផលកម្ពុជាទៅកាន់សហរដ្ឋអាម៉េរិក និងទីផ្សារអន្តរជាតិ ខណៈដែលសមាគមឧកញ៉ាកម្ពុជា រីករាយ និងស្វាគមន៍ជានិច្ចនូវការបង្កើតកិច្ចសហប្រតិបត្តិការនានាដែលនឹងនាំមកនូវអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មដល់សមាជិកទាំងអស់ទាំងលើការផ្លាស់ប្តូរបច្ចេកទេស បច្ចេកវិទ្យា ទិដ្ឋភាពច្បាប់ និងការនាំចេញនាំចូលផលិតផលរវាងប្រទេសទាំងពីរផងដែរ។

សូមបញ្ជាក់ថា កិច្ចពិភាក្សាធុរកិច្ចនេះបានកើតឡើងក្រោយពីប្រតិភូសមាគមឧកញ៉ាកម្ពុជា បានជួបពិភាក្សាការងារជាមួយភាគីសភាពាណិជ្ជកម្មកម្ពុជារដ្ឋកាលីហ្វ័រញ៉ាកាលពីពេលថ្មីៗកន្លងទៅនេះក្នុងពេលបំពេញបេសកកម្មផ្លាស់ប្តូរពាណិជ្ជកម្ម និងទាក់ទាញវិនិយោគ កាលពីថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០២៤ នៅសហរដ្ឋអាម៉េរិក និងកាណាដាដែលដឹកនាំដោយឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។




















## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ រួមជាមួយ ថ្នាក់ដឹកនាំ ក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាបានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសិកា លី ឃីម ដែលត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា ហ៊ុន ឡាក់អគ្គលេខាធិការនៃសមាគមឧកញ៉ាកម្ពុជា

នារសៀលថ្ងៃសៅរ៍ ១៤កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាអមដំណើរដោយ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបទៀតដែលជាថ្នាក់ដឹកនាំ ក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសិកា លី ឃីម ដែលត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជាដែលបានទទួលមរណភាពកាលពីថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ១២:០៩នាទីអធ្រាត្រ ក្នុងជន្មាយុ ៨៦ឆ្នាំដោយជរាពាធ។

ក្នុងវេលាប្រកបដោយទុក្ខសោកនេះលោកអ្នកឧកញ៉ាប្រធានបាននាំយកនូវសាររំលែកទុក្ខពីសមាគមឧកញ៉ាកម្ពុជាជូនចំពោះក្រុមគ្រួសារនៃសព ព្រមទាំងបានចុះហត្ថលេខាលើសៀវភៅក្រាំងមាសមរណទុក្ខផងដែរ។






























**ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ ទីក្រុងមេគង្គឃី (Mekong Quay City) ស្ថិតនៅក្រុងអរិយក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**



នាព្រឹកថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូប បានអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ទីក្រុងមេគង្គឃី (Mekong Quay City) ស្ថិតនៅក្រុងអរិយក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា គម្រោងទីក្រុងមេគង្គឃី មានផ្ទៃដីទំហំប្រមាណ ២១០ហិកតា វិនិយោគដោយក្រុមហ៊ុន ធីភី ម៉ូវ៉ាល់ គ្រុប និងក្រុមហ៊ុន យុន សៀ អ៊ីមផត អិចផត ហើយមានទីតាំងស្ថិតនៅតាមដងទន្លេមេគង្គទល់មុខទន្លេចតុមុខ ដែលនឹងរៀបចំសាងសង់ដោយបែងចែកជាផ្នែកសំខាន់ៗ ដូចជា ផ្នែកអគារពាណិជ្ជកម្មលក្ខណៈទំនើប, ផ្សារទំនើប, មជ្ឈមណ្ឌលអប់រំ, សណ្ឋាគារស្តង់ដាអន្តរជាតិ, មជ្ឈមណ្ឌលទេសចរណ៍ និងវប្បធម៌ ។ល។

**សម្តេចមហាបវរធិបតី** បានថ្លែងថា ការវិនិយោគសាងសង់គម្រោងកសាងទីក្រុងដ៏ធំនេះ គឺជាការវិនិយោគដ៏ត្រឹមត្រូវមួយដែលបានបង្ហាញយ៉ាងប្រត្យក្សថាវិស័យអចលនទ្រព្យនៅកម្ពុជាបាននិងកំពុងងើបឡើងវិញជាបណ្តើរៗ។ **សម្តេច** បានថ្លែងបន្ថែមថា ក្រោមម្លប់សុខសន្តិភាព ដែលបានកើតឡើងតាមរយៈនយោបាយឈ្នះ-ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាកម្ពុជា ប្រទេសកម្ពុជាបានវិវឌ្ឍន៍យ៉ាងខ្លាំង មិនត្រឹមតែក្នុងទិដ្ឋភាពនៃកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការប្រែប្រួលមុខមាត់នៃសង្គមជាតិទាំងមូលផង។

គួរបញ្ជាក់ដែរថាគម្រោងទីក្រុងមេគង្គឃីនេះនឹងចូលរួមចំណែកក្នុងការបំពេញក្តីប្រាថ្នារបស់ប្រជាជនផងនិងជំរុញដល់កំណើនសេដ្ឋកិច្ចជាតិជារួមផងតាមរយៈការជួយបង្កើនភាពសកម្មនៃវិស័យអចលនទ្រព្យ,វិនិយោគ, ពាណិជ្ជកម្ម, បដិសណ្ឋារកិច្ច, ក៏ដូចជាការជួយផ្សព្វផ្សាយវប្បធម៌ និងទេសចរណ៍របស់កម្ពុជាផងដែរ។





















## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឱ្យ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមានសន្តិភាព



នាព្រឹកថ្ងៃពុធ ១០រោចខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ខែធ្នូ ឆ្នាំ២០២៥ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ បានអនុញ្ញាតឱ្យលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមានសន្តិភាព។

ក្នុងឱកាសដ៏វិសេសវិសាលនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានមានប្រសាសន៍ថ្លែងអំណរគុណដល់វិស័យឯកជនតាមរយៈសមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ដែលបានចូលរួមចំណែកជាមួយមូលនិធិកសាងហេដ្ឋារចនាសម្ព័ន្ធតាមព្រំដែនផ្តោតលើការកសាងផ្លូវក្រវាត់ព្រំដែនក្រោមស្មារតីវប្បធម៌ចែករំលែក។ សម្តេចបានបន្ថែមថា៖ «នេះជាប្រវត្តិសាស្ត្ររបស់យើងដែលបានខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធ និងរុញការអភិវឌ្ឍទៅដល់ភូមិសាស្ត្រកន្ទុយនាគ និងកសាងបានខឿនការពារជាតិទៅដល់គ្រប់ទីកន្លែងនៃទឹកដីកម្ពុជាតាមរយៈការអភិវឌ្ឍផង និងប្រជាជនផង។»

ក្នុងឱកាសនៃជំនួប **សម្តេចធិបតី** បានវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណចំពោះសមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាដែលបានចូលរួមបរិច្ចាគថវិកាក្នុងមូលនិធិកសាងហេដ្ឋារចនាសម្ព័ន្ធតាមព្រំដែនដោយផ្តោតលើការកសាងផ្លូវក្រវាត់ព្រំដែននាពេលកន្លងមក។**សម្តេចធិបតី**បានគូសបញ្ជាក់ថាការកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយព្រំដែន ពិសេសផ្លូវក្រវាត់ព្រំដែននេះ គឺជាប្រវត្តិសាស្ត្រមួយដែលមិនត្រឹមតែជាការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ប៉ុណ្ណោះទេថែមទាំងជាខឿនការពារជាតិ,អធិបតេយ្យភាព,បូរណភាពទឹកដី,ជំរុញការអភិវឌ្ឍតំបន់ភូមិភាគព្សសាន,និងអនុញ្ញាតឱ្យកូនខ្មែរគ្រប់ជំនាន់បានធ្វើដំណើរដល់ព្រំដែនដែលមិនធ្លាប់បានធ្វើដំណើរទៅដល់ពីមុន។



**សម្តេច** បានបន្ថែមទៀតថា រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពារបូរណភាពទឹកដីនិងអធិបតេយ្យភាពមិនឱ្យបាត់បង់សម្រាប់កូនចៅគ្រប់ជំនាន់ទៅថ្ងៃអនាគត និងបានដាក់ទិសដៅដើម្បីប្រែក្លាយ និងអភិវឌ្ឍតំបន់ព្រំដែននៅក្នុងក្របខ័ណ្ឌទូទាំងប្រទេសនិយាយជារួម និងតំបន់ព្រំដែនភូមិភាគពាយ័ព្យសាននិយាយដោយឡែកទៅជាព្រំដែនដែលមានសក្តានុពលសេដ្ឋកិច្ច ដោយផ្តោតលើវិស័យកសិ-ឧស្សាហកម្ម ។

**សម្តេចធិបតី**បានជំរុញនិងលើកទឹកចិត្តឱ្យក្រុមហ៊ុនវិនិយោគក្នុងស្រុក ស្វែងរកឱកាស និងលទ្ធភាពបណ្តាក់ទុនឱ្យបានច្រើនបន្ថែមទៀតនៅតំបន់ទាំងនោះ។**សម្តេចធិបតី**បានសង្កត់ធ្ងន់ថានៅឆ្នាំ២០២៥ រាជរដ្ឋាភិបាលនឹងដាក់ចេញគោលនយោបាយ និងកញ្ចប់លើកទឹកចិត្តដល់ការវិនិយោគនៅតំបន់ព្រំដែន ជាពិសេស ការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម។

ឆ្លៀតក្នុងឱកាសនោះដែរ,**សម្តេចមហាបវរធិបតី**បានកោតសរសើរនិងវាយតម្លៃខ្ពស់ដល់ក្រុមការងារកសាង និងអភិវឌ្ឍហេដ្ឋានរចនាសម្ព័ន្ធតាមក្រវាត់ព្រំដែនដែលបានពុះពាររាល់ឧបសគ្គ និងការលំបាកនានា ជាមួយនឹងការប្តេជ្ញាចិត្ត ក្នុងការសម្រេចឱ្យបាន តាមផែនការដែលបានគ្រោងទុក។

សូមបញ្ជាក់ថា តបតាមការប្រកាសរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដោយបានសម្រេចបង្កើត «មូលនិធិកសាងហេដ្ឋារចនាសម្ព័ន្ធតាមព្រំដែន» ក្នុងគោលបំណងដើម្បីកៀរគរថវិកាបន្ថែមសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយព្រំដែនដោយផ្តោតលើការកសាងផ្លូវក្រវាត់ព្រំដែននោះ ថ្នាក់ដឹកនាំ ក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានចូលរួមបរិច្ចាគធនធានផ្ទាល់ខ្លួនដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងបុព្វហេតុការពារ និងអភិវឌ្ឍជាតិក្នុងស្មារតីមហាសាមគ្គីជាតិខ្មែរដើម្បីថែរក្សា សុខសន្តិភាព អធិបតេយ្យ និងបូរណភាពទឹកដី ក៏ដូចជាការជំរុញការអភិវឌ្ឍនៅតាមតំបន់ព្រំដែនឱ្យបានកាន់តែរឹងមាំ និងប្រកបដោយចីរភាព។



















## អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំ និងជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ ឡាយ ង៉ោ ដែលត្រូវជាម្ដាយបង្កើតរបស់ អ្នកឧកញ៉ា ហេង សៀ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា

នាល្ងាចថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ រួមជាមួយ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ដែលជាថ្នាក់ដឹកនាំ និងជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ ឡាយ ង៉ោ ដែលត្រូវជាម្ដាយបង្កើតរបស់អ្នកឧកញ៉ា ហេង សៀ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ដែលបានទទួលមរណភាពកាលពីថ្ងៃអង្គារ៍ ៩រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ៦:០៨នាទីល្ងាច ក្នុងជន្មាយុ ៨៥ឆ្នាំដោយជរាពាធ។

ក្នុងវេលាប្រកបដោយទុក្ខសោកនេះអ្នកឧកញ៉ាផៃហុកឈួនបាននាំយកនូវសាររំលែកទុក្ខពីសមាគមឧកញ៉ាកម្ពុជាជូនចំពោះក្រុមគ្រួសារនៃសព ព្រមទាំងបានចុះហត្ថលេខាលើសៀវភៅក្រាំងមាសមរណទុក្ខផងដែរ។











# បេសកកម្ម

១ តំណាង និងការពារផលប្រយោជន៍ក៏ដូចជាកិត្តិយសរបស់សមាជិក

២ កសាងទំនាក់ទំនងប្រកបដោយមិត្តភាព សាមគ្គីភាព
សហប្រតិបត្តិការ ក្នុងមហាគ្រួសារខ្មែរកញ្ញា

៣ ជួយគ្នាទៅវិញទៅមក ផ្លាស់ប្តូរព័ត៌មាន និងការពិគ្រោះយោបល់

៤ បង្កើនកិត្យានុភាព ឧត្តមភាព និងគុណធម៌របស់ខ្មែរកញ្ញាឱ្យកាន់តែរីកចម្រើន
និងរុងរឿងនាពេលអនាគតដោយផ្សារភ្ជាប់ការចូលរួមក្នុងសកម្មភាពសង្គម និងមនុស្សធម៌នានា

៥ លើកកម្ពស់ការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា
ក្នុងព្រះរាជាណាចក្រកម្ពុជា

៦ ជំរុញផ្សព្វផ្សាយសក្តានុពល និងកាលានុវត្តភាពនៃការវិនិយោគ
ក្នុងព្រះរាជាណាចក្រកម្ពុជា

៧ បង្កើតវេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងធុរកិច្ច ពាណិជ្ជកម្ម
ការវិនិយោគ និងវិស័យដទៃដើម្បីជាគុណប្រយោជន៍សម្រាប់សង្គមនិងសេដ្ឋកិច្ចជាតិ ។

# អត្ថប្រយោជន៍ក្នុងការក្លាយជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា

១ ក្លាយជាសមាជិកនៃមហាគ្រួសារឧកញ៉ាកម្ពុជាដែលប្រមូលផ្ដុំដោយគោរមវន្តជាលោកអ្នកឧកញ៉ាអ្នកឧកញ៉ា និងឧកញ៉ាដែលសុទ្ធសឹងជាធុរជនកំពុងប្រកបអាជីវកម្មលើពហុវិស័យប្រកបដោយកិត្តិនាមល្អនៅក្នុងប្រទេសកម្ពុជាដែលជាប្រភពទាក់ទាញដៃគូវិនិយោគទាំងក្នុងនិងក្រៅប្រទេស

២ ទទួលបានឯកសណ្ឋានគោរមងារឧកញ៉ាចំនួន ១ឈុត និងអាំងស៊ីងឧកញ៉ាធ្វើអំពីមាស ១៨K ចំនួន ១ផងដែរ

៣ ទទួលបាននូវការចុះឈ្មោះចូលក្នុងគេហទំព័រនិងបញ្ជីផ្លូវការនៃគោរមងារឧកញ៉ារបស់ស.ឧ.ក.ដែលបញ្ជាក់ពីភាពច្បាស់លាស់របស់សមាជិកម្នាក់ៗក្នុងនាមជាឧកញ៉ា

៤ ទទួលបានឱកាសចូលរួមក្នុងកម្មវិធីនានាដូចជាវេទិកាធុរកិច្ចការផ្គូផ្គងដៃគូពាណិជ្ជកម្មនិងការកសាងបណ្ដាញធុរកិច្ចជាមួយបណ្ដាគោរមវន្តជាសមាជិករបស់ស.ឧ.ក.ព្រមទាំងជាមួយធុរជនក៏ដូចជាវិនិយោគិនជាតិនិងអន្តរជាតិ

៥ ទទួលបាននូវការធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីច្បាប់  និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងគោរមងារឧកញ៉ា

៦ ទទួលបានការលើកតម្កើងបន្ថែមទៀតនូវគុណតម្លៃព្រមទាំងឧត្តមភាព    និងកិត្តិនាមនៃគោរមងារឧកញ៉ានៅក្នុងសង្គមតាមរយៈការផ្សព្វផ្សាយព័ត៌មានល្អៗចេញពី ស.ឧ.ក.

៧ ទទួលបានការគាំទ្រ និងការគាំពារ ទាំងផ្នែកច្បាប់ និងជំនួយស្មារតីក្នុងពេលមានបញ្ហា ឬវិវាទផ្សេងៗដោយឈរលើគោលការណ៍សាមគ្គីភាពដើម្បីដោះស្រាយបញ្ហាប្រឈម (ស្របច្បាប់) រួមគ្នា

៨ មានសិទ្ធិពេញលេញក្នុងការចូលរួមកិច្ចប្រជុំនិងពិធីជួបជុំនានារបស់ស.ឧ.ក.ដែលត្រូវបានរៀបចំឡើងដោយសមាគមឧកញ៉ាកម្ពុជា ជាពិសេសជំនួប និងការអមដំណើរប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាថ្នាក់ដឹកនាំនានានៅក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគព្រមទាំងសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ចជាដើម

## ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ

Website Facebook Telegram Youtube TikTok X(Twitter)

ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org